**JICA Cambodia Office - JICA カンボジア事務所**
June 21 at 4:11 PM ·

[កិច្ចប្រជុំគណៈកម្មការសម្របសម្រួលរួមលើកទី១ របស់គម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាកនៅប្រទេសកម្ពុជា/The 1st Joint Coordination Committee (JCC) Meeting of the Project for Strengthening of In-Service Training System in Cambodia (Strings)]

------------------------------------------------------------------------
នាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ កិច្ចប្រជុំលើកទី១របស់គណៈកម្មការសម្របសម្រួលរួម (JCC) និងពិធីប្រកាសដាក់ដំណើរការជាផ្លូវការនៃគម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅប្រទេសកម្ពុជា ត្រូវបានរៀបចំឡើងដោយជោគជ័យតាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងសុខាភិបាល និងទីភ្នាក់ងារ JICA ក្រោមអធិបតីភាព លោកជំទាវសាស្ត្រាចារ្យ តាន់ វួចឆេង រដ្ឋលេខាធិការនៃក្រសួងសុខាភិបាល និងមានការចូលរួមពីប្រធានអង្គភាព មកពីក្រសួងសុខាភិបាល ទីភ្នាក់ងារ JICA ប្រចាំប្រទេសកម្ពុជា ទីស្នាក់ការកណ្តាល JICA ប្រចាំប្រទេសជប៉ុន (តាមប្រព័ន្ធ Zoom) ស្ថានទូតជប៉ុនប្រចាំប្រទេសកម្ពុជា គណៈគិលានុបដ្ឋាកកម្ពុជា សមាគមគិលានុបដ្ឋាកកម្ពុជា បណ្តាមន្ទីរពេទ្យជាតិ មន្ទីរសុខាភិបាលរដ្ឋបាលខេត្ត និងមន្ទីរពេទ្យបង្អែកខេត្តនៅក្នុងខេត្តសាកល្បង (ខេត្តបាត់ដំបង និងខេត្តកំពង់ចាម) ផងដែរ ។
កិច្ចប្រជុំបានធ្វើការពិភាក្សាយ៉ាងសកម្មស្តីពីផែនការអនុវត្ត និងសកម្មភាពគម្រោង ពិសេសទាក់ទងនឹងគុណវឌ្ឍក្នុងការជ្រើសរើសគ្រូបណ្តុះបណ្តាលបង្គោល និងនីតិវិធីផ្លូវការសម្រាប់ចូលរួមសកម្មភាពគម្រោងជាដើម។ ទន្ទឹមនឹងនេះ វឌ្ឍនភាពនៃសកម្មភាពគម្រោងចាប់ពីខែមករាដល់ខែមិថុនា និងរបាយការណ៍នៃការប៉ាន់ប្រមាណតម្រូវការក្នុងខែមេសា និងខែឧសភា ក៏ត្រូវបានបង្ហាញផងដែរ។ ជាមួយគ្នានេះ អង្គប្រជុំក៏មានការឯកភាពគ្នា និងផ្តល់មតិវិជ្ជមានក្នុងការបង្កើតគោលការណែនាំថ្នាក់ជាតិស្តីពីការពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងាររបស់គិលានុបដ្ឋាកផងដែរ ៕
អត្ថបទ៖ អឹង សុដាវី ផ្នែកសុខាភិបាល ការិយាល័យចៃកាប្រចាំប្រទេសកម្ពុជា

On 15th of June 2022, the Ministry of Health and JICA Project for Strengthening In-service Training System in Cambodia successfully co-organized the 1st Joint Coordination Committee (JCC) and the Launching Ceremony at Raffles Hotel Le Royal under the presidency of H.E. Prof. Tan Vuoch Chheng (Secretary of State, Ministry of Health), and also key representatives from Ministry of Health, JICA Cambodia Office, JICA Headquarter in Japan (via Zoom), Embassy of Japan, Cambodian Council of Nurses (CCN), Cambodian Association of Nurses (CAN), national hospitals, administration provincial health departments and provincial hospitals in pilot provinces (Battambang & Kampong Cham).
At the JCC meeting, the operation plan and detailed activities for the project were actively discussed, especially for the selection criteria of trainers and official procedures for joining the activities, and so on. The progress of activities (Jan-June) and the interim report of need assessment (in April & May) were also shared. Positive comments on developing the draft of the national guidelines were expressed as well.

Credited: Oeng Sodavy, Health Sector, JICA Cambodia Office











